**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៣៥០...សហវ.ប្រក

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកំណត់កម្រៃសេវាកម្មចំពោះការបង្កើត និងកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម និងការពិន័យអន្តរការណ៍លើករណីល្មើសច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

<u>**សម្រេច**</u>

**ប្រការ១:** អនុញ្ញាតឱ្យយកកម្រៃសេវាកម្ម ចំពោះការចុះបញ្ជីសិប្បកម្ម ផ្តល់ប្រកាសបង្កើតរោងចក្រ និងសិប្បកម្ម វិញ្ញាបនបត្រដំណើរការរោងចក្រ និងសិប្បកម្ម និងលិខិតអនុញ្ញាត ។

**ប្រការ២:** កម្រៃសេវាកម្ម ត្រូវបានកំណត់ចំពោះការចុះបញ្ជីសិប្បកម្ម ផ្តល់ប្រកាសបង្កើតរោងចក្រ និងសិប្បកម្ម វិញ្ញាបនបត្រដំណើរការរោងចក្រ និងសិប្បកម្ម និងលិខិតអនុញ្ញាត មានដូចខាងក្រោម៖

| ល.រ | ពិពណ៌នា | ដើមទុន រោងចក្រ និងសិប្បកម្ម | កម្រៃសេវា | សុពលភាព |
|---|---|---|---|---|
| ១ | ចុះបញ្ជីសិប្បកម្ម | ដើមទុន តិចជាង ឬស្មើ ៥០.០០០ ដុល្លារ | ៥០.០០០ រៀល | អចិន្ត្រៃយ៍ |
| ២ | ប្រកាសបង្កើត រោងចក្រ និងសិប្បកម្ម | ដើមទុន តិចជាង ឬស្មើ ៥០.០០០ ដុល្លារ | ៥០.០០០ រៀល | អចិន្ត្រៃយ៍ |
| | | ដើមទុន ច្រើនជាង ៥០.០០០ ដុល្លារ ដល់ ២៥០.០០០ ដុល្លារ | ១០០.០០០ រៀល | |
| | | ដើមទុន ច្រើនជាង ២៥០.០០០ ដុល្លារ ដល់ ៥០០.០០០ ដុល្លារ | ២០០.០០០ រៀល | |
| | | ដើមទុន ច្រើនជាង ៥០០.០០០ ដុល្លារ | ៤០០.០០០ រៀល | |
| ៣ | វិញ្ញាបនបត្រដំណើរការ រោងចក្រ និងសិប្បកម្ម | ដើមទុន តិចជាង ឬស្មើ ៥០.០០០ ដុល្លារ | ២៥.០០០ រៀល | ០៣ឆ្នាំ |
| | | ដើមទុន ច្រើនជាង ៥០.០០០ ដុល្លារ ដល់ ២៥០.០០០ ដុល្លារ | ៥០.០០០ រៀល | |
| | | ដើមទុន ច្រើនជាង ២៥០.០០០ ដុល្លារ ដល់ ៥០០.០០០ ដុល្លារ | ១០០.០០០ រៀល | |
| | | ដើមទុនច្រើនជាង ៥០០.០០០ ដុល្លារ | ២០០.០០០ រៀល | |
| ៤ | លិខិតអនុញ្ញាត ពង្រីកផលិតកម្ម ប្តូរទីតាំង ប្តូរម្ចាស់ និង ប្តូរឈ្មោះ រោងចក្រ និងសិប្បកម្ម | ដើមទុន តិចជាង ឬស្មើ ៥០.០០០ ដុល្លារ | ២៥.០០០ រៀល | តាមការស្នើសុំ |
| | | ដើមទុន ច្រើនជាង ៥០.០០០ ដុល្លារ ដល់ ២៥០.០០០ ដុល្លារ | ៥០.០០០ រៀល | |
| | | ដើមទុន ច្រើនជាង ២៥០.០០០ ដុល្លារ ដល់ ៥០០.០០០ ដុល្លារ | ១០០.០០០ រៀល | |
| | | ដើមទុនច្រើនជាង ៥០០.០០០ ដុល្លារ | ២០០.០០០ រៀល | |

ប្រការ៣: យោងតាម ជំពូកទី៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ទឹកប្រាក់ពិន័យអន្តរការណ៍ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវអនុវត្តដូចខាងក្រោម៖

| បទល្មើស | ទឹកប្រាក់ពិន័យ |
| --- | --- |
| -ក្នុងករណី បង្កើតសិប្បកម្មដែលតម្រូវឱ្យស្នើសុំចុះបញ្ជីដោយពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងពុំបានធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត ដែលខ្លួនបាន បោះទីតាំងក្នុងរយៈពេល ០៧ថ្ងៃ ក្រោយថ្ងៃដំណើរការ (មាត្រា ៤៣)។ | ពី ៥០០.០០០ រៀល ទៅ ២.៥០០.០០០ រៀល |
| -ក្នុងករណី បង្កើតប្រភេទសិប្បកម្ម ដែលចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយគ្មានការអនុញ្ញាត (មាត្រា ៤៣)។ | ពី ១.០០០.០០០ រៀល ទៅ ៥.០០០.០០០ រៀល |
| -ក្នុងករណី ពង្រីក ឬបង្កើតសាខា ឬផ្លាស់ប្តូរទីតាំងរោងចក្រ ពុំមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល(មាត្រា៤៤)។ | ពី២.០០០.០០០រៀល ទៅ ១០.០០០.០០០រៀល |
| -ក្នុងករណី ប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មី ពុំបានធ្វើការសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី (មាត្រា ៤៤)។ | |
| -ក្នុងករណី ម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាព តាមផ្លូវច្បាប់ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ពុំបានធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ៤៥ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណៈភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ (មាត្រា ៤៤)។ | |
| -ក្នុងករណី ម្ចាស់រោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេលមួយខែមុនថ្ងៃដែលរោងចក្របញ្ឈប់ដំណើរការជាស្ថាពរ (មាត្រា ៤៤)។ | |
| -ក្នុងករណី ម្ចាស់រោងចក្រពុំបានតាំងបង្ហាញប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហ នៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ(មាត្រា ៤៤)។ | |
| -ក្នុងករណី បាត់បង់ប្រកាសបង្កើតរោងចក្រ ឬ/និង លិខិតអនុញ្ញាតទាំងឡាយ ម្ចាស់រោងចក្រពុំបានធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀត មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបាត់បង់ (មាត្រា ៤៤)។ | |

<table>
<tr><td>-ក្នុងករណី រោងចក្រពុំមានផ្លាកឈ្មោះ ពុំបានលើកបង្ហាញផ្លាកឈ្មោះរោងចក្រនៅកន្លែងងាយមើលឃើញ ខាងមុខរោងចក្រ ហើយផ្លាកឈ្មោះរោងចក្រពុំបានសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅលើអក្សរផ្សេងៗទៀត (មាត្រា ៤៤)។</td><td rowspan="8">ពី២.០០០.០០០រៀល ទៅ ១០.០០០.០០០រៀល</td></tr>
<tr><td>-ក្នុងករណី ផ្លាស់ប្តូរឈ្មោះរោងចក្រ ដោយគ្មានការយល់ព្រមពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (មាត្រា ៤៤)។</td></tr>
<tr><td>-ក្នុងករណី មានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឲ្យរោងចក្រផ្អាកដំណើរការទាំងស្រុងលើសពី ៧ថ្ងៃ ហើយម្ចាស់រោងចក្រពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ (មាត្រា ៤៤)។</td></tr>
<tr><td>-ក្នុងករណី រោងចក្រមិនមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមាន:<br>• ប្រព័ន្ធប្រកាសភាពអាសន្ន និងមធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ<br>• សញ្ញាប្រយ័ត្នអគ្គីភ័យ នៅកន្លែងដែលចាំបាច់<br>• ទ្វារសង្គ្រោះយ៉ាងតិចបំផុតមានចំនួនពីរ នៅតាមជាន់នីមួយៗ<br>• ផ្លូវសង្គ្រោះ សម្រាប់រថយន្តពន្លត់អគ្គីភ័យ<br>• មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត<br>• ប្លង់បំព្លញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន។<br>(មាត្រា ៤៦)</td></tr>
<tr><td>-ក្នុងករណី ម៉ាស៊ីន ឬផ្នែកនៃម៉ាស៊ីនដែលអាចបង្កឲ្យមានគ្រោះថ្នាក់ជាយថាហេតុ មិនមានគម្រប ឬឧបករណ៍ការពារ (មាត្រា ៤៦)។</td></tr>
<tr><td>-ក្នុងករណី មិនមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬបំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ (មាត្រា ៤៦)។</td></tr>
<tr><td>-ក្នុងករណី ប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គីមីគ្រោះថ្នាក់ ឬឧស្ម័នក្នុងផលិតកម្ម មិនបានប្រតិបត្តិតាមលក្ខណៈបច្ចេកទេសដែលធានាបាននូវសុវត្ថិភាព (មាត្រា ៤៦)។</td></tr>
<tr><td>-ក្នុងករណី ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយ ឧបករណ៍ ឬធុងដែលប្រើសម្ពាធខ្ពស់ មិនមានការត្រួតពិនិត្យ និងអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុនពេលដំណើរការ (មាត្រា ៤៦)។</td></tr>
</table>

**ប្រការ៤:** ការគ្រប់គ្រងចំណូលពីកម្រៃសេវាកម្ម និងពីការពិន័យអន្តរការណ៍ដូចមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង មន្ទីរ អង្គភាពក្រោមឱវាទក្រសួង ត្រូវបង់ចំណូលដែលប្រមូលបានចូលថវិការដ្ឋ និងធ្វើរបាយការណ៍ពីចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀតទាត់។

**ប្រការ៥:** ការបង់កម្រៃសេវាកម្ម និងប្រាក់ពិន័យអន្តរការណ៍ដូចមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យករចំណូល ។

**ប្រការ៦:** ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់អង្គភាពប្រមូលចំណូល នឹងត្រូវកំណត់ក្នុងប្រកាសអន្តរក្រសួងមួយដោយឡែក បន្ទាប់ពីមានគោលការណ៍ពីរាជរដ្ឋាភិបាល ។

**ប្រការ៧:** តារាងកម្រៃសេវាកម្ម និងតារាងទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវបិទប្រកាសផ្សព្វផ្សាយនៅនឹងអង្គភាពប្រមូលចំណូល ។

**ប្រការ៨:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៩:** គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ១០:** ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** |
| គាត ឈន់ | ស៊ុយ សែម |

<u>*ចម្លងជូន:*</u>

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *នាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *គ្រប់សាលារាជធានី ខេត្ត*
- *ដូចប្រការ ៩ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*